**នៅចំពោះមុខ អង្គជំនុំជម្រះតុលាការកំពូល**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ភាគីដាក់ឯកសារ: សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៥

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 29-Sep-2015, 14:38
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ: **សាធារណៈ/Public**

ឋានៈនៃចំណាត់ថ្នាក់ឯកសារ:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សារណាតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ទៅនឹងសំណើលើកទីប្រាំមួយ របស់ នួន ជា ពាក់ព័ន្ធនឹងភស្តុតាងបន្ថែមលើបណ្ដឹងសាទុក្ខ**

---

**ដាក់ដោយ៖**

**សហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី៖**

ពេជ អង្គ

Marie GUIRAUD

**សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

ជេត វណ្ណលី

ហុង គឹមសួន

គឹម ម៉េងឃី

ឡោ ជុនធី

ម៉ុច សុវណ្ណារី

ស៊ិន សុវ៉ន

**នៅចំពោះមុខ៖**

**អង្គជំនុំជម្រះតុលាការកំពូល៖**

ចៅក្រម គង់ ស្រ៊ឹម ជាប្រធាន

ចៅក្រម A. KLONOWIECKA-MILART

ចៅក្រម សោម សិរីវឌ្ឍ

ចៅក្រម C. N. JAYASIINGHE

ចៅក្រម ម៉ុង មុន្នីចរិយា

ចៅក្រម យ៉ា ណារិន

**ចៅក្រម** Florence Ndepele MWACHANDE-MUMBA

សំ សុគង់

វ៉ែន ពៅ

ទី ស្រ៊ុនណា

Philippe CANONNE
Laure DESFORGES
Ferdinand DJAMMEN NZEPA
Elodie DULAC
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Yiqiang Y. LIU
Daniel LOSQ
Christine MARTINEAU
Lyma NGUYEN
Mahesh RAI
Nushin SARKARATI

**ផ្ញើជូន៖**

**ការិយាល័យសហព្រះរាជអាជ្ញា៖**

ជា លាង

Nicholas KOUMJIAN

**ជនជាប់ចោទ៖**

ខៀវ សំផន

នួន ជា

**សហមេធាវីការពារក្តី៖**

សុន អរុណ

Victor KOPPE

គង់ សំអុន

Anta GUISSÉ
Arthur VERCKEN

**មេធាវីប្រចាំការ៖**

ទូច វរល័ក្ស

Calvin SAUNDERS

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

Olivier BAHOUGNE
Patrick BAUDOUIN
Beini YE

## I. សេចក្តីផ្តើម

1. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ("សហមេធាវីនាំមុខ") សូមធ្វើការឆ្លើយតបទៅនឹង សំណើទីប្រាំមួយរបស់ នួន ជា សុំឲ្យពិចារណា និងទទួលយកភស្តុតាងបន្ថែម ទាក់ទិននឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ ("សំណើ") តទៅនេះហៅថា "សារណាតប"[1]។

2. សហមេធាវីនាំមុខមានចំណាប់អារម្មណ៍ ក្នុងការឆ្លើយតបទៅនឹងខ្លឹមសារនៃសំណើ ក្នុងវិសាលភាពដែលសំណើនោះប៉ះពាល់ដល់គុណប្បភាពនៃសិទ្ធិរបស់ភាគី រួមទាំងដើមបណ្តឹងរដ្ឋប្បវេណីផងដែរ។ ហេតុនេះ សហមេធាវីនាំមុខសូមឆ្លើយតបទៅនឹងខ្លឹមសារនៃសំណើ តែទទួលយកការសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងការចេញសេចក្តីសម្រេចទៅលើសំណូមពរដែលសហមេធាវីនាំមុខស្នើឡើង។

## II. ប្រវត្តិនីតិវិធី

3. នៅថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានចេញសាលក្រម ក្នុងសំណុំរឿង ០០២/០១ ដោយផ្តន្ទាទោស នួន ជា *ក្នុងចំណោមនោះ* ពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលក្នុងនោះមានការធ្វើមនុស្សឃាត ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងទៀត (ដែលរួមមានការផ្លាស់ទីលំនៅដោយបង្ខំ និងការធ្វើឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស) នៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី ១), ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងទៀត (ដែលរួមមានការផ្លាស់ទីលំនៅដោយបង្ខំ និងការធ្វើឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស) នៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី ២) និងការធ្វើមនុស្សឃាត និងការសម្លាប់រង្គាលនៅទួលពោធិ៍ជ្រៃ ដែលបានប្រព្រឹត្តនៅលើទឹកដីនៃប្រទេសកម្ពុជាក្នុងអំឡុងថ្ងៃទី ១៧ ខែ មេសា ឆ្នាំ

---

[1] សំណើលើកទី ៦ របស់ នួន ជា ស្នើសុំឲ្យមានការពិចារណា និងទទួលយកភស្តុតាងបន្ថែម ទាក់ទិននឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៅក្នុងសំណុំរឿង ០០២/០១ ឯកសារ **F2/8** ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១៥។

១៩៧៥ និងបញ្ចប់នៅឆ្នាំ ១៩៧៧ ដោយសម្រេចផ្តន្ទាទោស នួន ជា ដាក់ពន្ធនាគារអស់មួយជីវិត[2]។

4. នៅថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ សហជនជាប់ចោទបានដាក់សេចក្តីជូនដំណឹងរបស់ខ្លួនអំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល[3] បន្ទាប់មកបានដាក់សារណាលើបណ្តឹងសាទុក្ខនៅថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤[4]។ នៅថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៥ សហព្រះរាជអាជ្ញាបានដាក់ចម្លើយតបរបស់ខ្លួន (“ចម្លើយតបរបស់ ក.ស.ព”)[5]។

5. នៅថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៤ អង្គជំនុំជម្រះតុលាការកំពូលបានទទួលយកមួយផ្នែកនូវសំណើរបស់សហមេធាវីនាំមុខ ដែលអនុញ្ញាតឱ្យពួកគេដាក់ចម្លើយតបរួមគ្នា ដើម្បីឆ្លើយតបទៅនឹងសារណាលើបណ្តឹងសាទុក្ខដែលបានដាក់ដោយក្រុមមេធាវីការពារក្តីទាំងពីរក្រុម ដោយស្ថិតក្នុងដែនកំណត់ត្រឹមតែមូលដ្ឋាននានាដែលប៉ះពាល់ដោយផ្ទាល់ទៅនឹងសិទ្ធិ និងផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី និងដែលព្យាយាមបញ្ចៀសនូវភាពច្រំដែល និងភាពជាន់គ្នាទៅលើបញ្ហានានាដែលមានរួចហើយនៅក្នុងចម្លើយតបរបស់ ក.ស.ព[6]។

## III. ច្បាប់ជាធរមាន

6. វិធាន ២១(១) នៃវិធានផ្ទៃក្នុងចែងថា៖ “ដំណើរការនីតិវិធីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់

---

[2] សាលក្រមក្នុងសំណុំរឿង ០០២/០១ ឯកសារ **E313** ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ ទំព័រ ៩៧៨-៩៨១ (“សាលក្រម”)។ *សូមមើលផងដែរ ដូចយោងខាងលើ* កថាខណ្ឌ ៩៤០។

[3] *សូមមើល* សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ ឯកសារ **E313/1/1** ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ (“សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ នួន ជា”)។

[4] បណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ ឯកសារ **F16** ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ (“បណ្តឹងសាទុក្ខរបស់ នួន ជា”)។

[5] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខ ក្នុងសំណុំរឿង ០០២/០១ ឯកសារ **F17/1** ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៥ (“ចម្លើយតបរបស់សហព្រះរាជអាជ្ញា”)។

[6] សេចក្តីសម្រេចលើសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ឯកសារ **F10/2** ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៤ កថាខណ្ឌ ១៧ (“សេចក្តីសម្រេចលើសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខ”)។ *សូមមើលផងដែរ* សំណើសុំរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងបណ្តឹងសាទុក្ខនៅក្នុងសំណុំរឿង ០០២/០១ ឯកសារ **F10** ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤។

ភាគីទាំងឡាយ” ហើយថា “អង្គជំនុំជម្រះវិសាមញ្ញត្រូវធានាថា ជនរងគ្រោះត្រូវទទួលបានការជូនព័ត៌មាន ហើយសិទ្ធិរបស់ជនរងគ្រោះត្រូវបានការពារក្នុងអំឡុងពេលនៃដំណើរការនីតិវិធីរឿងក្តី”។ វិធាន ២១(៤) នៃវិធានផ្ទៃក្នុងចែងថា “ការចោទប្រកាន់ចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញត្រូវធ្វើការជំនុំជម្រះក្នុងរយៈពេលមួយសមស្រប។

7. វិធាន ១២*ស្ទួនពីរ* (១) នៃវិធានផ្ទៃក្នុងចែងថា “សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវធានាឲ្យមានប្រសិទ្ធិភាពអំពីការរៀបចំ ការតំណាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចាប់ពីដំណាក់កាលជំនុំជម្រះឡើងទៅ ដែលធ្វើឲ្យមានតុល្យភាពនូវសិទ្ធិរបស់ភាគីទាំងអស់និងតម្រូវការឲ្យការជំនុំជម្រះប្រព្រឹត្តទៅបានឆាប់រហ័ស ក្នុងបរិបទពិសេសរបស់ អ.វ.ត.ក”។ ជាងនេះទៀតអនុលោមតាមវិធាន ១២*ស្ទួនពីរ* (២) នៃវិធានផ្ទៃក្នុង សហមេធាវីនាំមុខមានកាតព្វកិច្ចលើកកំពស់ “យុត្តិធម៌ និងដំណើរការនីតិវិធីប្រកបដោយភាពត្រឹមត្រូវនិងមានប្រសិទ្ធិភាព”។

8. នៅថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៥ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា ដើមបណ្តឹងរដ្ឋប្បវេណី “ទទួលបានសិទ្ធិក្នុងការជំនុំជម្រះប្រកបដោយយុត្តិធម៌ដែលមានចែងក្នុងមាត្រា ១៤(១) នៃ [កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ]” និងមាន “តួនាទីជាក់លាក់ និងមានកម្រិតនៅក្នុងកិច្ចដំណើរការនីតិវិធី ដូចដែលមានចែងក្នុងវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក”[7]។

9. នៅក្នុងសាលក្រមលើបណ្តឹងសាទុក្ខនៃរឿងក្តី *ឌុច* អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា នៅលើបណ្តឹងសាទុក្ខ “ភាគីមិនអាចលើកឡើងវិញនូវទទឡ្ហីករណ៍ដែលត្រូវបានបដិសេធនៅក្នុងដំណាក់កាលជំនុំជម្រះសាលាដំបូងនោះទេ ដរាបណាភាគីអាចបង្ហាញថាសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបដិសេធទទឡ្ហីករណ៍ទាំងនេះ គឺជាកំហុសមួយដែលទាមទារឲ្យមានការអន្តរាគមន៍ពីអង្គជំនុំជម្រះតុលាការកំពូល”[8]។

10. បើតាមវិធាន ១០៨(៧) នៃវិធានផ្ទៃក្នុងចែងថា “ភាគីអាចស្នើសុំបន្ថែមភស្តុតាងចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល យោងតាមវិធាន ៨៧(៣) បើសិនជាភស្តុតាងនោះ មិនអាចរកបានក្នុងពេលសវនាការ ហើយដែលអាចជាកត្តាកំណត់នាំឲ្យឈានដល់ការធ្វើសេចក្តីសម្រេចនៅក្នុងសវនាការ។ សេចក្តីស្នើសុំបន្ថែមភស្តុតាងត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពីទំនាក់ទំនងដោយផ្ទាល់រវាង

---

[7] សេចក្តីសម្រេចលើសំណើសុំបន្ថែមពេលវេលារបស់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់សួរដេញដោលសាក្សី SCW-5 ឯកសារ **F26/2/2** ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៥ កថាខណ្ឌ ៧។

[8] សាលដីកាក្នុងរឿងក្តី *ឌុច* កថាខណ្ឌ ២០។ *សូមមើលផងដែរ* សាលដីកាក្នុងរឿងក្តី *Brđanin* កថាខណ្ឌ ១៦។

ភ័ស្តុតាងបន្ថែមថ្មីនោះ ជាមួយនឹងសម្អាងហេតុជាក់លាក់ ដែលអង្គជំនុំជម្រះសាលាដំបូងបានលើក។ ភាគីផ្សេងទៀតដែលរងការប៉ះពាល់ដោយសេចក្តីស្នើសុំនេះ អាចធ្វើការឆ្លើយតបក្នុងរយៈពេល ១៥ ថ្ងៃ ចាប់ពីថ្ងៃទទួលបានការជូនដំណឹងអំពីសេចក្តីស្នើសុំនោះ”។

11. បើតាមវិធាន ១០៤(១) នៃវិធានផ្ទៃក្នុង “អង្គជំនុំជម្រះតុលាការកំពូលត្រូវសម្រេចលើបណ្តឹងសាទុក្ខ ជំទាស់ទៅនឹងសាលក្រមលើអង្គសេចក្តី ឬសេចក្តីសម្រេចនៃអង្គជំនុំជម្រះសាលាដំបូង ដោយផ្អែកលើមូលដ្ឋានដូចខាងក្រោម៖ ក. កំហុសលើអង្គច្បាប់ដែលនាំអោយមោឃៈសាលក្រមលើអង្គសេចក្តី ឬសេចក្តីសម្រេចនោះ ឬ ខ. កំហុសនៃអង្គហេតុដែលនាំអោយសាលក្រមលើអង្គសេចក្តី ឬសេចក្តីសម្រេចនោះមានភាពមិនយុត្តិធម៌”។ ជាងនេះទៀត បណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងអាចផ្អែកលើកំហុសដែលពាក់ព័ន្ធក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបណ្តាលឲ្យប៉ះពាល់ដល់ម្ចាស់បណ្តឹងសាទុក្ខ។ សម្រាប់គោលបំណងទាំងនេះ អង្គជំនុំជម្រះតុលាការកំពូលអាចពិនិត្យទៅលើភ័ស្តុតាង និងកោះហៅភ័ស្តុតាងថ្មីដោយខ្លួនឯងបាន ដើម្បីសម្រេចទៅលើបញ្ហានោះ។ បើតាមខ្លឹមសារនៃវិធាន ១០៤ *ស្ទួន* នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះតុលាការកំពូល បានពិចារណាលើអំណាចនេះដើម្បីកោះហៅ “ភ័ស្តុតាងថ្មី” ដែលស្ថិតក្រោមលក្ខខណ្ឌនានានៃវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។ វិធាន ៨៧(៣) នៃវិធានផ្ទៃក្នុងអនុវត្តចំពោះករណីទាំងពីរ គឺសំណើសុំដាក់ភ័ស្តុតាងបន្ថែមតាមវិធាន ១០៤(១) នៃវិធានផ្ទៃក្នុង និងសំណើនានាតាមវិធាន ១០៨(៧) នៃវិធានផ្ទៃក្នុង។

## IV. សារណា

12. សហមេធាវីនាំមុខសូមឆ្លើយតបទៅនឹងសំណើក្នុងនាមក្រុមដើមបណ្តឹងរដ្ឋប្បវេណីរួម ដែលមានកាតព្វកិច្ចលើកកំពស់យុត្តិធម៌ និងដំណើរការនីតិវិធីប្រកបដោយភាពត្រឹមត្រូវនិងមានប្រសិទ្ធភាព[9]។ ហេតុនេះ នៅក្នុងសារណាតបនេះ សហមេធាវីនាំមុខមិនបានស្នើសុំសំណូមពរជាក់លាក់ពីអង្គជំនុំជម្រះតុលាការកំពូល ទាក់ទិននឹងលទ្ធផលនៃសំណើ ដោយសារអង្គជំនុំជម្រះនឹងពិចារណាទៅលើការព្រួយបារម្ភដែលកើនឡើង ដែលនឹងលើកឡើងខាងក្រោម នៅពេលសម្រេចទៅលើខ្លឹមសារនៃសំណើ។

[9] វិធាន ១២*ស្ទួនពីរ* (២) នៃវិធានផ្ទៃក្នុង។

13. សហមេធាវីនាំមុខសូមលើកជាទឡ្ហីករណ៍ថា សំណើពាក់ព័ន្ធនឹងសមាសភាពនៃសហឧក្រិដ្ឋកម្មរួម ដែលមិនត្រូវបានជំទាស់នៅក្នុងសារណាលើបណ្តឹងសាទុក្ខរបស់ នួន ជា ហើយថា សារណាលើបណ្តឹងសាទុក្ខរបស់ នួន ជា លើកឡើងនូវកំហុសនានាដែលត្រូវបានចោទប្រកាន់ ទាក់ទិននឹងការទទួលខុសត្រូវរបស់ថ្នាក់លើ ដែលមិនត្រូវបានធ្វើជាមូលដ្ឋាននៃការផ្តន្ទាទោសរបស់សហជនជាប់ចោទ។ ទាក់ទិននឹងការព្រួយបារម្ភទាំងនេះ សហមេធាវីនាំមុខសូមលើកឡើងថា តុល្យភាពនៃសិទ្ធិរបស់ភាគីនឹងមិនអាចរក្សាបានទេ ប្រសិនបើសំណើត្រូវបានទទួលយក។

## ក. សារណាលើបណ្តឹងសាទុក្ខរបស់ នួន ជា មិនជំទាស់ទៅនឹងសមាជិកភាពនៃសហឧក្រិដ្ឋកម្មរួមទេ

14. សារណាលើបណ្តឹងសាទុក្ខរបស់ នួន ជា ជំទាស់ *ក្នុងចំណោមនោះ* ការកំណត់លក្ខណៈរបស់បក្សកុម្មុយនីស្តកម្ពុជា ថាជា "ស្ថាប័នរួបរួមគ្នា មានឋានានុក្រមតឹងរ៉ឹង និងមានទម្រង់ជាពីរ៉ាមីត"[10] តួនាទីរបស់ នួន ជា នៅក្នុងគោលនយោបាយផ្នែកឃោធា ការអនុវត្ត និងសន្តិសុខផ្ទៃក្នុង[11] សេចក្តីសន្និដ្ឋានលើគោលនយោបាយដែលពាក់ព័ន្ធនឹង "ការកម្ទេចខ្មាំង"[12] សេចក្តីសន្និដ្ឋានពាក់ព័ន្ធនឹងទួលពោធិ៍ជ្រៃ[13] និយមន័យនៃសហឧក្រិដ្ឋកម្មរួម ("JCE")[14] និយមន័យនៃ "សហឧក្រិដ្ឋកម្មរួមរបស់បក្សកុម្មុយនីស្តកម្ពុជា"[15] គោលនយោបាយសហឧក្រិដ្ឋកម្មនៃការកំណត់គោលដៅចំពោះមន្ត្រីនៃរបបសាធារណរដ្ឋខ្មែរ[16] និងការចូលរួមចំណែកធំធេងរបស់ នួន ជា ទៅនឹងបទឧក្រិដ្ឋនានាដែលត្រូវបានចោទប្រកាន់[17]។ ទោះជាយ៉ាងក្តី ការជំទាស់មួយទៅនឹងអង្គហេតុនៃសមាជិកភាព និង/ឬសមាសភាពនៃសហឧក្រិដ្ឋកម្មរួមមិនត្រូវបានលើកឡើងជាក់ស្តែងទេ។ សារណាលើបណ្តឹងសាទុក្ខរបស់ នួន ជា មិនបានជំទាស់ថា ការពិត សមាជិកនានានៃសហឧក្រិដ្ឋកម្មរួម រួមទាំង នួន ជា ផងជាផ្នែកនៃសហឧក្រិដ្ឋកម្មរួម។

---

[10] បណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២២៥-២៤៩។

[11] បណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៥០-២៦៧។

[12] បណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៦៨-២៨៣។

[13] បណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៤៩-៤៦៦។

[14] បណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៨៤-៤៩៣។

[15] បណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៩៤-៤៩៨។

[16] បណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៥២៦-៦១៥។

[17] បណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៦១៦-៦២៦។

15. ទោះបី សារណាលើបណ្តឹងសាទុក្ខរបស់ នួន ជា ដកស្រង់ផ្នែកសម្រេចសេចក្តីនៃសាលក្រមដែលកំណត់សមាសភាពនៃសហឧក្រិដ្ឋកម្មរួម ពោលគឺ កថាខណ្ឌ ៧៧៧ ក៏ដោយ[18] ក៏ខ្លឹមសារនៃទឡ្ហីករណ៍ពុំមានទឡ្ហីករណ៍ពាក់ព័ន្ធនឹង*អង្គហេតុ*នៃសមាសភាពនៃសហឧក្រិដ្ឋកម្មរួម ឬសមាជិកភាពរបស់ វស់ ញឹម សោ ភឹម និងអ្នកផ្សេងទៀតទេ។ ការជំទាស់ក្នុងសារណាលើបណ្តឹងសាទុក្ខរបស់ នួន ជា ពាក់ព័ន្ធនឹងសេចក្តីសន្និដ្ឋានទៅលើចរិតលក្ខណៈ និយមន័យ និងវិសាលភាពនៃគោលបំណងរួម និងមិនពាក់ព័ន្ធនឹងសមាជិកភាពទេ៖

> “លើសពីនេះទៀត សំអាងហេតុនេះមិនសមហេតុផល និងមិនស៊ីសង្វាក់គ្នាជាមួយនឹងសំអាងហេតុផ្សេងៗទៀតនៅក្នុងសាលក្រម។ អង្គជំនុំជម្រះមិនបានយល់ឃើញថា បក្សកុម្មុយនីស្តកម្ពុជាបានខិតខំបន្ទាបបន្ថោក ធ្វើទុក្ខបុកម្នេញ ឬបំភិតបំភ័យប្រជាជនកម្ពុជាទូទៅឡើយ ប៉ុន្តែខិតខំសម្រេចឲ្យបាននូវបដិវត្តសង្គមនិយមមួយក្នុងចំណោមប្រជាជនទាំងនោះ។ បដិវត្តនោះ ពាក់ព័ន្ធនឹង ការងារកសិកម្ម*សមូហភាព*ឆ្ពោះទៅរកគោលដៅកសាងប្រទេស។ យោងតាមអង្គជំនុំជម្រះ គោលបំណងនៃគោលនយោបាយខ្លាំងដែលបានសន្មតនេះ គឺដើម្បីការពារបដិវត្តតែមួយគត់ប៉ុណ្ណោះ។ គោលនយោបាយក្នុងការ “បង្កើតបរិយាកាសមិនប្រាកដប្រជា” ដោយចេតនា ដោយធ្វើឲ្យមានការពិបាកក្នុងការដឹងអំពីអ្វីដែលជាអំពើហាមឃាត់នោះ ពុំមានទំនាក់ទំនងសមហេតុផលទៅនឹងគោលបំណងរបស់បក្សកុម្មុយនីស្តកម្ពុជាដែលបានចោទប្រកាន់នោះឡើយ”[19]។ [...]
>
> “បន្ទាប់ពីទទួលបានដីកាបញ្ជូនរឿងទៅជំនុំជម្រះរួចមក អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា មនុស្សជាច្រើននាក់ ក្នុងនោះមាន នួន ជា ផងដែរ “បានចែករំលែកគោលបំណងរួមដើម្បី “បង្កើតបដិវត្តន៍សង្គមនិយមយ៉ាងឆាប់រហ័ស តាមរយៈមធ្យោបាយចាំបាច់” ដូចជា “មហាលោតផ្លោះ” និងដើម្បីការពារបក្សប្រឆាំងនឹងសត្រូវផ្ទៃក្នុង ក៏ដូចជាសត្រូវខាងក្រៅផងដែរ” និងថា ការគ្រាន់តែមានគោលបំណងរួមដូច្នេះ គឺមិនមានភាពគ្រប់គ្រាន់ ឬមានលក្ខណៈឧក្រិដ្ឋទាំងស្រុងនោះទេ” ។ មេធាវីការពារក្តីយល់ស្របថា នួន ជា បានចូលរួមក្នុងគោលបំណងរួមនេះជាមួយមេដឹកនាំដទៃទៀតនៃបក្សកុម្មុយនីស្តកម្ពុជា ដើម្បីបង្កើតបដិវត្តន៍សង្គមនិយមយ៉ាងឆាប់រហ័ស និងដើម្បីការពារបដិវត្តន៍នោះ។ ប៉ុន្តែ អង្គជំនុំជម្រះមានកំហុសអង្គហេតុ និងអង្គច្បាប់ ក្នុងការសម្រេចថា គោលបំណងរួមនេះមានជាប់ពាក់ព័ន្ធនឹងការការពារបក្ស “តាមរយៈមធ្យោបាយចាំបាច់ណាមួយ”។ អង្គ

[18] បណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៨២, ៤៩៤។

[19] បណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៨២ (លុបចោលការយោងខាងក្នុង)។

ជំនុំជម្រះខកខានមិនបានពន្យល់អំពីខ្លឹមសារនៃការសម្រេចនេះទេ គឺអត្ថន័យធម្មតាដែលថា មិនមានវិធានការបែបណាមួយហួសពីវិសាលភាពនៃគោលនយោបាយរបស់បក្សនោះទេ”[20]។

16. សារណាលើបណ្តឹងសាទុក្ខរបស់ នួន ជា ពិតជាបានលើកជាទឡ្ហីករណ៍ថា បក្សកុម្មុយនីស្តកម្ពុជាជាស្ថាប័នបែងចែកបក្ខពួក និងបានស្វែងរកការគាំទ្រខ្លួន តាមមធ្យោបាយនៃទឡ្ហីករណ៍បន្ថែមទៀតដែលបានលើកឡើងនៅក្នុងសារណាលើបណ្តឹងសាទុក្ខ រួមទាំង តាមរយៈសំណើសុំភ័ស្តុតាងបន្ថែមលើបណ្តឹងសាទុក្ខ។ ទោះជាយ៉ាងណាក្តី សារណាលើបណ្តឹងសាទុក្ខនេះបានធ្វើឡើងដោយផ្អែកលើទឡ្ហីករណ៍ដែលទាក់ទិននឹងកំហុសដែលត្រូវបានចោទប្រកាន់នៅក្នុងគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួម[21] ជាជាងជំទាស់ទៅនឹងសេចក្តីសន្និដ្ឋានលើអង្គហេតុ និងអង្គច្បាប់ស្តីពីសមាសភាពនៃសហឧក្រិដ្ឋកម្មរួម និងសមាជិកភាពតែម្តង។

17. សហមេធាវីនាំមុខកត់សម្គាល់ថា នៅពេលកំណត់សមាសភាពនៃសហឧក្រិដ្ឋកម្មរួម សាលក្រមមិនបានយកតួនាទីរបស់បុគ្គលម្នាក់នៅក្នុងបក្សកុម្មុយនីស្តកម្ពុជាមកធ្វើជាមូលដ្ឋាននៃសេចក្តីសន្និដ្ឋានពីសមាជិកភាពទេ។ សេចក្តីសន្និដ្ឋានទាំងនេះមិនមែនសំដៅលើ ថាតើបក្សកុម្មុយនីស្តកម្ពុជាត្រូវបាន ឬមិនត្រូវបានកំណត់លក្ខណៈថាជា “ស្ថាប័នរួបរួមគ្នា មានឋានានុក្រមតឹងរ៉ឹង និងមានទម្រង់ជាពីរ៉ាមីត” ដូចដែលត្រូវបានលើកឡើងនៅសារណាលើបណ្តឹងសាទុក្ខរបស់ នួន ជា ទេ។ សេចក្តីសន្និដ្ឋានលើអង្គច្បាប់លើកឡើងថា៖

> “ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា យ៉ាងយូរបំផុតត្រឹមខែ មិថុនា ឆ្នាំ ១៩៧៤ រហូតដល់ ខែ ធ្នូ ឆ្នាំ ១៩៧៧ មនុស្សជាច្រើនមានគោលបំណងរួមដើម្បី “បង្កើតបដិវត្តន៍សង្គម

---

[20] បណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ កថាខណ្ឌ ៩៩៥។

[21] សារណាលើបណ្តឹងសាទុក្ខរបស់ នួន ជា ជំទាស់ទៅនឹងសហឧក្រិដ្ឋកម្មរួម តាមរយៈមូលដ្ឋាននៃបណ្តឹងសាទុក្ខដែលកំហិតត្រឹមតែចរិតលក្ខណៈ និងនិយមន័យនៃគោលបំណងរួម ពោលគឺ “បង្កើតបដិវត្តន៍សង្គមនិយមយ៉ាងឆាប់រហ័សតាមរយៈមធ្យោបាយចាំបាច់ “មហាលោតផ្លោះ មហាអស្ចារ្យ” និងដើម្បីការពារបក្សប្រឆាំងនឹងសត្រូវផ្ទៃក្នុង ក៏ដូចជាសត្រូវខាងក្រៅ” (សាលក្រម កថាខណ្ឌ ៧៧៧)។ ដោយមិនបានសន្និដ្ឋានថាគោលបំណងបែបនេះជាបទឧក្រិដ្ឋពីធម្មជាតិ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ការអនុវត្តគោលបំណងនេះបណ្តាលឲ្យ និង/ឬ ពាក់ព័ន្ធនឹងការប្រព្រឹត្តិបទឧក្រិដ្ឋ។ ឃ្លាដែលសារណាលើបណ្តឹងសាទុក្ខរបស់ នួន ជាបានផ្តល់ចំណាប់អារម្មណ៍គឺ “តាមមធ្យោបាយចាំបាច់ណាមួយ” ដើម្បីបង្ហាញថា វាអាចសំដៅដល់ប្រភេទនៃអំពើទាំងអស់ ទោះមានលក្ខណៈជាបទឧក្រិដ្ឋ ឬលក្ខណៈផ្សេងក៏ដោយ (សារណាលើបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៤៩៦)។ ទោះជាយ៉ាងណាក្តី សារណាលើបណ្តឹងសាទុក្ខមិនបានយកចិត្តទុកដាក់ថា វាក៏មានការអនុវត្តបដិវត្តសង្គមនិយម “យ៉ាងឆាប់រហ័ស” ដែលរួមបញ្ចូលទាំងលក្ខណៈជាបទឧក្រិដ្ឋនូវ*ការអនុវត្ត* ដោយទទួលស្គាល់ថា គោលបំណងនៃបដិវត្តន៍សង្គមនិយមត្រូវបានពិនិត្យពីបរិបទនៃល្បឿនរបស់វាដែលបានគ្រោងទុក។

និយមយ៉ាងឆាប់រហ័សតាមរយៈមធ្យោបាយចាំបាច់តាម "សន្ទុះមហាលោតផ្លោះ" និងដើម្បីការពារបក្សប្រឆាំងនឹងសត្រូវផ្ទៃក្នុង ក៏ដូចជាសត្រូវខាងក្រៅ"។ <u>សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មាធិការមជ្ឈិម រដ្ឋមន្ត្រីនៃរដ្ឋាភិបាល លេខាភូមិភាគ និងលេខាតំបន់ស្វយ័ត រួមទាំង នួន ជា ខៀវ សំផន ប៉ុល ពត អៀង សារី សុន សេន វន វ៉េត តា ម៉ុក សោ ភឹម រស់ ញឹម កុយ ធួន កែ ពក ចាន់ សំ ជូ ជេត ប៊ូ ផាត យ៉ុង យ៉េម ប៊ិន ណាន អៀង ធីរិទ្ធ និង ម៉ី ប្រាង គឺជាសមាជិកនៃក្រុមដែលមានគោលបំណងរួមដូចបានបញ្ជាក់នេះ</u>។ ភ័ស្តុតាងបង្ហាញថា គោលបំណងរួមក្នុងការការពារ និងកសាងប្រទេសឲ្យបានឆាប់រហ័សតាមរយៈបដិវត្តន៍សង្គមនិយមនេះ ផ្អែកតាមគោលការណ៍រក្សាការសម្ងាត់ ឯករាជ្យ អធិបតេយ្យ ប្រជាធិបតេយ្យប្រមូលផ្តុំ ខ្លួនទីពឹងខ្លួន និងសមូហភាវូបនីយកម្ម ត្រូវបានបង្កើតឡើងយ៉ាងច្បាស់លាស់នៅត្រឹមខែ មិថុនា ឆ្នាំ ១៩៧៤ និងបានបន្តមានអត្ថិភាពយ៉ាងហោចណាស់ រហូតដល់ខែ ធ្នូ ឆ្នាំ ១៩៧៧"[22]។

18. ជាងនេះទៀត សហមេធាវីនាំមុខបន្ថែមថា សមាជិកភាពនៃសហឧក្រិដ្ឋកម្មរួមមិនបានសន្មតជាមុននូវឋានានុក្រម ឬមិនបានលើកឡើងដោយប្រយោលនូវរចនាសម្ព័ន្ធជាទម្រង់ពីវ៉ាមីតដែលចាំបាច់របស់ស្ថាប័នទេ។ តាមរយៈសេចក្តីសន្និដ្ឋានលើអង្គហេតុ និងអង្គច្បាប់នៃសាលក្រម វាបង្ហាញច្បាស់ថា ការសម្រេចពីសមាជិកភាពនៃសហឧក្រិដ្ឋកម្មរួមមិនមានទំនាក់ទំនងជាសំខាន់ទៅនឹងរចនាសម្ព័ន្ធចាត់តាំងរបស់បក្សកុម្មុយនីស្តកម្ពុជាទេ តែផ្ទុយទៅវិញ វាមានទំនាក់ទំនងទៅនឹងវត្តមានរបស់សមាជិកដែលបានលើកឡើងទាំងនោះ ក្នុងការជួបប្រជុំជាមួយគ្នា។

19. ដោយកត់សម្គាល់ថា អ្នកចូលរួមសំខាន់បំផុតទៅក្នុងគោលបំណងរួមមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥[23] សាលក្រមបានសំអាងសេចក្តីសន្និដ្ឋានរបស់ខ្លួនជាសេចក្តីសន្និដ្ឋានលើអង្គច្បាប់ទៅលើសមាជិកភាពនៃសហឧក្រិដ្ឋកម្មរួម ក្នុងអំឡុងពេលនៃយុត្តាធិការលើពេលវេលា គឺពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ខែ ធ្នូ ឆ្នាំ ១៩៧៧។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើភ័ស្តុតាង និងសេចក្តីសន្និដ្ឋានលើអង្គហេតុ ដែលទាក់ទិននឹងវត្តមាននៃអ្នកចូលរួមនៅក្នុងមហាសន្និបាតបក្សលើកទី១ នៅខែ កញ្ញា ឆ្នាំ ១៩៦០[24] មហាសន្និបាតបក្សលើកទី២ នៅខែ កុម្ភៈ ឆ្នាំ ១៩៦៣[25] កិច្ច

---

[22] សាលក្រម កថាខណ្ឌ ៧៧៧ (គូសបញ្ជាក់បន្ថែម)។

[23] សាលក្រម កថាខណ្ឌ ៧២៥។

[24] សាលក្រម កថាខណ្ឌ ៧២៦៖ "ក្នុងពេលមហាសន្និបាតបក្សលើកទី១ ក្នុងខែ កញ្ញា ឆ្នាំ ១៩៦០ ទូ សាមុត (លេខា) នួន ជា (អនុលេខា) ប៉ុល ពត សុន សេន អៀង សារី វន វ៉េត សោ ភឹម និងអ្នកផ្សេងទៀត បានអនុម័តកម្មវិធីនយោបាយបីចំណុច ដែលក្នុងនោះមាន ការប្រយុទ្ធប្រឆាំងនឹងចក្រពត្តិនិយម ការរំដោះប្រទេស និងប្រជាជន និងការធ្វើបដិវត្តន៍ឲ្យបានជោគជ័យ"។

ប្រជុំនៅខែ មករា ឆ្នាំ ១៩៦៨[26] និងខែ តុលា ឆ្នាំ ១៩៧០[27] មហាសន្និបាតបក្សលើកទី៣ នៅឆ្នាំ ១៩៧១[28] ការរៀបចំផែនការនៅខែ មិថុនា ឆ្នាំ ១៩៧៤[29] កិច្ចប្រជុំចន្លោះខែ មេសា ដល់ខែ ធ្នូ ឆ្នាំ ១៩៧៥[30] ចរិតលក្ខណៈនៃសមាជិកភាព និងសមាសភាពនៃគណៈកម្មាធិការអចិន្ត្រៃយ៍[31] កិច្ចប្រជុំ

---

[25] សាលក្រម កថាខណ្ឌ ៧២៧៖ "ក្នុងពេលមហាសន្និបាតបក្សលើកទី២ ក្នុងខែ កុម្ភៈ ឆ្នាំ ១៩៦៣ ប៉ុល ពត (ដែលនៅពេលនោះជាលេខាបក្ស) នួន ជា (អនុលេខា) អៀង សារី វន វេត រស់ ញឹម តា ម៉ុក សោ ភឹម និងទំនងជាមាន សុន សេន ព្រមទាំងអ្នកផ្សេងទៀត បានលើកឡើងបញ្ជាក់អំពីមាគ៌ាបក្សដែលត្រូវបានអនុម័តនៅក្នុងមហាសន្និបាតបក្សលើកទី១ ដោយមាគ៌ាទាំងនោះរួមទាំងបដិវត្តន៍នយោបាយ និងបដិវត្តន៍ប្រដាប់អាវុធ" (លុបចោលការយោងខាងក្នុង)។

[26] សាលក្រម កថាខណ្ឌ ៧២៩៖ "នៅក្នុងខែ មករា ឆ្នាំ ១៩៦៨ នួន ជា បានកោះប្រជុំមួយនៅក្នុងទីក្រុងភ្នំពេញជាមួយនឹងមេដឹកនាំភូមិភាគមួយចំនួន រួមទាំង សោ ភឹម រស់ ញឹម និង តា ម៉ុក។ ពួកគេបានពិភាក្សារួមគ្នាអំពីភាពចាំបាច់ត្រូវចាប់ផ្ដើមការតស៊ូប្រដាប់អាវុធប្រឆាំងនឹងអ្នកកាន់អំណាច ពោលគឺ ក្រុម លន់ នល់ ដែលកំពុងគ្រប់គ្រងរដ្ឋាភិបាលនាពេលនោះ នៅតាមតំបន់ដែលពួកគេយល់ឃើញថា ក្រុម លន់ នល់ កំពុងធ្វើ "សកម្មភាពជិះជាន់សង្កត់សង្កិន" មកលើពួកគេកាន់តែខ្លាំងឡើង" (លុបចោលការយោងខាងក្នុង)។

[27] សាលក្រម កថាខណ្ឌ ៧៣២៖ "នៅក្នុងខែ តុលា ឆ្នាំ ១៩៧០ គណៈកម្មាធិការមជ្ឈិម រួមទាំង ប៉ុល ពត នួន ជា អៀង សារី តា ម៉ុក សោ ភឹម កុយ ធួន និងលេខាភូមិភាគផ្សេងទៀត បានពិភាក្សាអំពីផែនការរំដោះប្រទេសកម្ពុជាពីពួកចក្រពត្តិអាមេរិក និងរបបសាធារណរដ្ឋខ្មែរ ហើយបានបញ្ជាក់អំពីគោលនយោបាយខ្លួនទីពឹងខ្លួន និងគោលនយោបាយឯករាជ្យរបស់បក្ស" (លុបចោលការយោងខាងក្នុង)។

[28] សាលក្រម កថាខណ្ឌ ៧៣៣៖ "នៅក្នុងមហាសន្និបាតបក្សលើកទី៣ ក្នុងឆ្នាំ ១៩៧១ នួន ជា ប៉ុល ពត ខៀវ សំផន (នៅពេលនោះ ជាសមាជិកត្រៀមនៃគណៈកម្មាធិការមជ្ឈិម) អៀង សារី កុយ ធួន កែ ពក ឌឿន សោ ភឹម វន វេត តា ម៉ុក រស់ ញឹម និងអ្នកផ្សេងទៀត បានសម្រេចប្ដូរឈ្មោះបក្សទៅជាបក្សកុម្មុយនីស្តកម្ពុជា ហើយបានបង្កើតភូមិភាគពិសេសមួយនៅក្បែរទីក្រុងភ្នំពេញ ព្រមទាំងបានបញ្ជាក់ជាថ្មីអំពីមាគ៌ាបក្សតាំងពីពេលមហាសន្និបាតបក្សលើកទី១ និងលើកទី២ រួមទាំងបានប្ដេជ្ញាតស៊ូវណ្ណៈផងដែរ" (លុបចោលការយោងខាងក្នុង)។

[29] សាលក្រម កថាខណ្ឌ ៧៣៥៖ "នៅក្នុងខែ មិថុនា ឆ្នាំ ១៩៧៤ សមាជិក និងសមាជិកត្រៀមនៃគណៈកម្មាធិការមជ្ឈិម ដែលមាន ប៉ុល ពត នួន ជា ខៀវ សំផន សោ ភឹម កុយ ធួន តា ម៉ុក វន វេត រស់ ញឹម និង សុន សេន តាមគោលការណ៍ប្រជាធិបតេយ្យប្រមូលផ្ដុំ បានរៀបចំផែនការវាយសម្រុកចុងក្រោយដើម្បីរំដោះប្រទេស និងជម្លៀសប្រជាជនចេញពីខេត្ត-ក្រុងឲ្យទៅរស់នៅតាមទីជនបទនានា" (លុបចោលការយោងខាងក្នុង)។

[30] សាលក្រម កថាខណ្ឌ ៧៤១៖ "ចន្លោះពីខែ មេសា ឆ្នាំ ១៩៧៥ ដល់ ខែ ធ្នូ ឆ្នាំ ១៩៧៧ អ្នកទាំងនោះរួមមាន រស់ ញឹម (ពាយ័ព្យ) សោ ភឹម (បូព៌ា) តា ម៉ុក (និរតី) ជូ ជេត (បស្ចឹម) កុយ ធួន (ភូមិភាគកណ្ដាល (ឧត្តរចាស់) រហូតដល់ ឆ្នាំ ១៩៧៥) កែ ពក (ភូមិភាគកណ្ដាល (ឧត្តរចាស់) ចាប់ពីឆ្នាំ ១៩៧៥) ចាន់ សំ (ភូមិភាគឧត្តរ ចាប់ពីពេលបង្កើតឡើងនៅអំឡុងឆ្នាំ ១៩៧៧) ម៉ែន សាន (ឦសាន) ប៊ូ ផាត (តំបន់ ១០៣ រហូតដល់ពេលតំបន់នេះត្រូវច្របាច់បញ្ចូលជាមួយភូមិភាគឧត្តរ ក្នុងអំឡុងឆ្នាំ ១៩៧៧) យ៉ុង យ៉ែម (តំបន់ ៥០៥ រហូតដល់ ឆ្នាំ ១៩៧៦) និង ប៊ិន ណាន (តំបន់ ៥០៥ ចាប់ពីឆ្នាំ ១៩៧៦)" (លុបចោលការយោងខាងក្នុង)។

នៅខែ កញ្ញា ឆ្នាំ ១៩៧៥[32] សមាជិកភាពនៃសភាតំណាងប្រជាជន[33] កិច្ចប្រជុំជាទៀងទាត់នៅក្រុងភ្នំពេញ[34] កិច្ចប្រជុំនៅតាមភូមិភាគ និងទំនាក់ទំនងតាមរយៈទូរលេខ[35]។

---

[31] សាលក្រម កថាខណ្ឌ ៧៤៥៖ "គណៈកម្មាធិការអចិន្ត្រៃយ៍ដែលបានចាប់ផ្តើមឡើងក្នុងអំឡុងខែ សីហា ឆ្នាំ ១៩៧៥ ដែលរួមមានទាំងសមាជិកពេញសិទ្ធិ គឺ នួន ជា ប៉ុល ពត អៀង សារី សោ ភឹម តា ម៉ុក វន វ៉េត (ជាសមាជិកពេញសិទ្ធិ ឬ សមាជិកត្រៀម) និង សុន សេន (ជាសមាជិកត្រៀម ឬ សមាជិកបំរុង) ផងដែរនោះ បានជួបប្រជុំទៀងរាល់សប្តាហ៍ ហើយនៅក្នុងពេលបន្ទាន់ ការប្រជុំនេះអាចលើសពីម្តងក្នុងមួយសប្តាហ៍" (លុបចោលការយោងខាងក្នុង)។

[32] សាលក្រម កថាខណ្ឌ ៧៤៩៖ "អៀង សារី បានបញ្ជាក់ថា គាត់មានវត្តមាននៅក្នុងកិច្ចប្រជុំថ្នាក់ដឹកនាំបក្ស កាលពីខែ កញ្ញា ឆ្នាំ ១៩៧៥ ដែលក្នុងកិច្ចប្រជុំនោះក៏មានវត្តមានរបស់ ខៀវ សំផន ប៉ុល ពត នួន ជា សោ ភឹម សុន សេន តា ម៉ុក វ៉ន វេត រស់ ញឹម កុយ ធួន និងមេបញ្ជាការយោធាមួយចំនួនទៀត ដែលពិភាក្សាអំពីបញ្ហាការពារ កសិកម្ម "បញ្ហាទឹក" និងឧស្សាហកម្ម" (លុបចោលការយោងខាងក្នុង)។

[33] សាលក្រម កថាខណ្ឌ ៧៦៦៖ "បន្ទាប់មក សភាតំណាងប្រជាជនបានជ្រើសតាំងរដ្ឋាភិបាលថ្មីជាផ្លូវការ ដែល ខៀវ សំផន គឺជាប្រធានរដ្ឋ ហើយ សោ ភឹម និង រស់ ញឹម ត្រូវបានតែងតាំងជាអនុប្រធានរដ្ឋនៃគណៈប្រធានរដ្ឋ។ ក្រោយមក ខៀវ សំផន បានពន្យល់ថា គាត់ទទួលយកតួនាទីជាប្រធាននេះដោយសារតែជាភារកិច្ចស្នេហាជាតិ ហើយគាត់មិនចង់ឲ្យចលនាមួយនេះចុះអន់ខ្សោយនោះទេ""។ ប៉ុល ពត ត្រូវបានតែងតាំងជានាយករដ្ឋមន្ត្រី នួន ជា ជាប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាតំណាងប្រជាជន អៀង សារី ជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស សុន សេន ជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការការពារជាតិ វន វ៉េត ជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកផ្នែកសេដ្ឋកិច្ច ហ៊ូ នឹម ជារដ្ឋមន្ត្រីក្រសួងឃោសនាការ និងព័ត៌មាន ជួន ជឿន ជារដ្ឋមន្ត្រីក្រសួងសុខាភិបាល អៀង ធីរិទ្ធ ជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ច តូច ភឿន ជារដ្ឋមន្ត្រីក្រសួងសាធារណការ យុន យ៉ាត ជារដ្ឋមន្ត្រីក្រសួងវប្បធម៌ បណ្តុះបណ្តាល និងអប់រំ" (លុបចោលការយោងខាងក្នុង)។

[34] សាលក្រម កថាខណ្ឌ ៧៧២៖ "ក្រៅពីការចូលរួមក្នុងកិច្ចប្រជុំរបស់មជ្ឈិម កម្មាភិបាល និងលេខាភូមិភាគ និងលេខាតំបន់ស្វយ័ត ដូចជា រស់ ញឹម ក៏បានមកទីក្រុងភ្នំពេញយ៉ាងទៀងទាត់ ដើម្បីជួបប្រជុំជាមួយមេដឹកនាំបក្ស ក្នុងនោះ រួមទាំង ជាមួយ នួន ជា ផងដែរ។ មេដឹកនាំបក្ស រួមទាំង ប៉ុល ពត ខៀវ សំផន និង នួន ជា បានដឹកនាំវគ្គរៀនសូត្រក្នុងទីក្រុងភ្នំពេញ ដោយបានចាប់ផ្តើមវគ្គរៀនសូត្រទាំងនោះ ភ្លាមៗ ក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងបានបន្តគ្រប់ពេលក្នុងអំឡុងសម័យកម្ពុជា ប្រជាធិបតេយ្យ។ ពួកគេបានធ្វើបទឧទ្ទេសនាមចំពោះកម្មាភិបាលភូមិភាគ តំបន់ និងស្រុក ព្រមទាំង កម្មាភិបាលធម្មតា អំពីការកំណត់អត្តសញ្ញាណ និងការកម្ចាត់ខ្មាំង ការបន្តធ្វើការតស៊ូប្រដាប់អាវុធ ការបង្កើតសហករណ៍ ការលើកភ្លឺស្រែ ជីកប្រឡាយ និងការបំពេញការងារ និងបង្កបង្កើនផលតាមផែនការកំណត់" (លុបចោលការយោងខាងក្នុង)។

[35] សាលក្រម កថាខណ្ឌ ៧៧៣៖ "ដឹកនាំបក្ស រួមទាំង ប៉ុល ពត នួន ជា ខៀវ សំផន និង អៀង ធីរិទ្ធ ក៏បានធ្វើដំណើរទៅតាមភូមិភាគនានាដើម្បីសង្កេតមើលដំណើរការបដិវត្តន៍សង្គមនិយម និងដើម្បីជួបប្រជុំជាមួយនឹងកម្មាភិបាល និងមេដឹកនាំភូមិភាគផងដែរ។ យោងតាមសាក្សី សួគ្រ ទៀង នួន ជា ធ្វើដំណើរទៅខេត្តបាត់ដំបងដើម្បីជួបប្រជុំជាមួយនឹង រស់ ញឹម ទៀងរាល់ ៣ ទៅ ៤ ខែម្តង។ លើសពីនេះទៀត ទូរលេខមួយចំនួនដែលនៅសេសសល់ពីឆ្នាំ ១៩៧៧ ដល់ ឆ្នាំ ១៩៧៨ បង្ហាញថា កម្មាភិបាល និងលេខាភូមិភាគ ដូចជា រស់ ញឹម និង សោ ភឹម បានរាយការណ៍ជូនអង្គការ ឬ ថ្នាក់ដឹកនាំ ដោយបានចម្លងជូន ប៉ុល ពត សុន សេន វន វ៉េត នួន ជា និង/ឬ មន្ទីរ ៨៧០ អំពីអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ និងស្ថានការណ៍ខ្មាំងផ្សេងទៀត និងអំពី

20. សហមេធាវីនាំមុខលើកឡើងថា ពុំមានការជំទាស់ណាមួយក្នុងចំណោមការជំទាស់ដែលបានលើកឡើងនៅក្នុងកថាខណ្ឌ ១៤ នៃសារណាតបនេះបានរារាំងមិនឲ្យមេធាវីការពារក្តី នួន ជា ជំទាស់ទៅនឹងសមាសភាពរបស់សហឧក្រិដ្ឋកម្មរួម និង/ឬ សមាជិកភាពរបស់គាត់ លើបណ្តឹងសាទុក្ខទេ។ ទោះជាយ៉ាងណាក្តី តាមរយៈសំណើ នួន ជា ពោលអះអាងថា "ផ្ទុយខ្លាំងណាស់ពីសេចក្តីសន្និដ្ឋានដែលថា ប៉ុល ពត និង នួន ជា មានគោលបំណងរួមជាមួយគ្នា ហើយជាក់ស្តែងបានសហការគ្នាក្នុងសហឧក្រិដ្ឋកម្មរួម ជាមួយបណ្តាមេដឹកនាំទាំងអស់ដែលមានបំណងបង្កការបះបោរ និង/ឬអំពើក្បត់ប្រឆាំងនឹងពួកគេ"[36]។

21. ការជំទាស់នេះគួរតែត្រូវបានលើកឡើងនៅក្នុងសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ពួកគេ ដើម្បីឲ្យអង្គជំនុំជម្រះតុលាការកំពូលទទួលយកកំហុសដែលបានចោទប្រកាន់ទាំងនោះទៅដោះស្រាយ ហើយបន្ទាប់មក ពួកគេគួររៀបចំ លើកទឡ្ហីករណ៍ និងដាក់បង្ហាញកំហុសទាំងនោះនៅក្នុងសារណាលើបណ្តឹងសាទុក្ខរបស់ខ្លួន។

22. ការជំទាស់នេះមិនអាចត្រូវបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលតាមរយៈមធ្យោបាយនៃសំណើសុំភ័ស្តុតាងបន្ថែមដែលដកចេញនីតិវិធី និងសារធាតុដែលអង្គជំនុំជម្រះតុលាការកំពូលទទួលយកមកពិចារណា ជាពិសេស ដោយហេតុថា ចៅក្រមបានចូលដល់ដំណាក់កាលនៃការពិភាក្សាដើម្បីចេញសេចក្តីសម្រេចទៅលើខ្លឹមសារនៃបណ្តឹងសាទុក្ខ និងសារណាតបនានាដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះរួចទៅហើយ។

23. ក្នុងវិសាលភាពដែលភ័ស្តុតាងបន្ថែមពាក់ព័ន្ធនឹងសមាសភាពនៃសហឧក្រិដ្ឋកម្មរួម និងសមាជិកភាពនៃសហឧក្រិដ្ឋកម្មរួម សំណើមិនបានបំពេញតាមលក្ខខណ្ឌនានានៃវិធាន ១០៨(៧) ឬ វិធាន ១០៤(១) នៃវិធានផ្ទៃក្នុងនោះទេ។ ហេតុនេះ សហមេធាវីនាំមុខលើកឡើងថា ដោយពុំមានការជំទាស់ដែលមានសំអាងហេតុទៅនឹងសមាជិកភាពនៃសហឧក្រិដ្ឋកម្មរួម ការលើកទឡ្ហីករណ៍ដែលថា បក្សកុម្មុយនីស្តកម្ពុជាមានលក្ខណៈបែកបាក់ ទោះបីទំនងជាមានលក្ខណៈជាព័ត៌មានក៏ដោយ ក៏វាអាចពាក់ព័ន្ធនឹងការសម្រេចពីការទទួលខុសត្រូវរបស់ថ្នាក់លើ ជាទម្រង់នៃការទទួលខុសត្រូវប៉ុណ្ណោះ។

---

ការវាយប្រយុទ្ធនៅតាមព្រំដែនជាមួយនឹងវៀតណាម។ ពួកគេក៏បានស្នើសុំការណែនាំផ្សេងៗផងដែរ" (លុបចោលការយោងខាងក្នុង)។

[36] សំណើ កថាខណ្ឌ ១៣។

## ខ. សាលក្រមមិនបានសន្និដ្ឋានថា សហជនជាប់ចោទមានពិរុទ្ធភាពក្នុងនាមជាថ្នាក់លើទេ

24. សារណាលើបណ្តឹងសាទុក្ខរបស់ នួន ជា លើកឡើងនូវកំហុសលើអង្គច្បាប់ និងអង្គហេតុ ប្រឆាំងនឹងសេចក្តីសន្និដ្ឋានដែលអង្គជំនុំជម្រះសាលាដំបូងបានធ្វើ នៅពេលសន្និដ្ឋានថា នួន ជា គ្រប់គ្រងយ៉ាងមានប្រសិទ្ធភាពទៅលើបុគ្គលដែលទទួលខុសត្រូវចំពោះបទឧក្រិដ្ឋដែលបានប្រព្រឹត្ត តែមិនជំទាស់ទៅនឹងសេចក្តីសន្និដ្ឋាននានាដែលត្រូវបានយកមកពិចារណាទេ[37]។ នៅក្នុងសំណើ មេធាវីការពារក្តី "អះអាងឡើងវិញ និងសំអាង" លើទឡ្ហីករណ៍ទាំងនោះដែល ខ្លួនធ្លាប់បានលើកឡើងរយចមកហើយនៅក្នុងសារណាបញ្ចប់ការពិភាក្សាដេញដោលសម្រាប់សំណុំរឿង ០០២/០១[38]។ សំណើពោលអះអាងថា "ផ្ទុយខ្លាំងណាស់ពីសេចក្តីសន្និដ្ឋានដែលថា [...] នួន ជា បានធ្វើការគ្រប់គ្រងយ៉ាងមានប្រសិទ្ធទៅលើកងកម្លាំងមេដឹកនាំស៊ីវិល និងយោធា"[39]។ សំណើក៏បានកំណត់អំពីសេចក្តីសន្និដ្ឋាននានាទាក់ទិននឹងការទទួលខុសត្រូវរបស់ថ្នាក់លើថាជា "ការផ្តន្ទាទោសតាមវិធីផ្សេង" មួយ[40]។

25. សហមេធាវីនាំមុខសូមគូសបញ្ជាក់ថា សាលក្រមបានសន្និដ្ឋានថា សហជនជាប់ចោទ *ទទួលខុសត្រូវ* ក្នុងនាមជាថ្នាក់លើ តែមិនបានបញ្ចូលការផ្តន្ទាទោសតាមរយៈការទទួលខុសត្រូវរបស់ថ្នាក់លើថាជាទម្រង់នៃការទទួលខុសត្រូវមួយនោះទេ[41]។ សាលក្រមបានពិចារណាពីតួនាទីជាថ្នាក់លើរបស់សហជនជាប់ចោទ នៅពេលសម្រេចពីស្ថានទម្ងន់នានាទាក់ទិននឹងសម្រេចផ្តន្ទាទោសទេ[42]។

26. អាស្រ័យហេតុនេះ ថាតើ សហជនជាប់ចោទបាន ឬមិនបានដើរតួនាទីជាថ្នាក់លើ ឬដើរតួនាទីតាមវិធីផ្សេង និង/ឬ ការគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាពរបស់គាត់ទៅអ្នកក្រោមបង្គាប់មានវិសាល

---

[37] បណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៦៨១-៦៩៧។

[38] សំណើ កថាខណ្ឌ ៩។

[39] សំណើ កថាខណ្ឌ ១៣។

[40] សំណើ កថាខណ្ឌ ១៣។

[41] សាលក្រម កថាខណ្ឌ ៩៤១។

[42] សាលក្រម កថាខណ្ឌ ១០៨៤៖ "ការចូលរួមចំណែករបស់ នួន ជា នៅក្នុងឧក្រិដ្ឋកម្មទាំងអស់នេះ រួមមាន តាមរយៈការចូលរួមរបស់គាត់នៅក្នុងសហឧក្រិដ្ឋកម្មរួម ត្រូវបានធ្វើឡើងតាមរយៈតួនាទី ជាផ្លូវការរបស់គាត់ជាច្រើន ដូចជា ក្នុងនាមជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា នៅគ្រប់ពេលក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ និងក្នុងនាមជាសមាជិកពេញសិទ្ធិនៃគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា។ ការចូលរួមចំណែកនេះគឺជាការរំលោភបំពានលើតួនាទីដែលមានអំណាច និងមានឥទ្ធិពលរបស់គាត់ ដូច្នេះបង្កើតបានជាស្ថានទម្ងន់ទោស" (លុបចោលការយោងខាងក្នុង)។

ភាពបែបណា ក៏មិនអាចយកមកធ្វើជាសំអាងសម្រាប់ការជំទាស់ដែលពាក់ព័ន្ធនឹងសេចក្តីសន្និដ្ឋាននៃការផ្តន្ទាទោសពីបទសហឧក្រិដ្ឋកម្មរួមដែរ។ ហេតុនេះ សម្រាប់អង្គជំនុំជម្រះតុលាការកំពូលក្នុងការទទួលយក និងពិចារណាលើភ័ស្តុតាងបន្ថែម ដែលសារណាលើបណ្តឹងសាទុក្ខរបស់ នួន ជា មិនជំទាស់ទៅនឹងសមាជិកភាព ឬការកំណត់ទោសនោះ នឹងមិនបង្កើនការស្វែងរកការពិតលើបណ្តឹងសាទុក្ខទេ។ អនុលោមតាមសំអាងនេះ សំណើមិនបំពេញតាមលក្ខខណ្ឌតម្រូវនៃវិធាន ១០៨(៧) ឬ ១០៤(១) នៃវិធានផ្ទៃក្នុងទេ។

27. ទោះបីគេត្រូវសន្មតថា សារណាលើបណ្តឹងសាទុក្ខរបស់ នួន ជា លើកទឡ្ហីករណ៍ទាក់ទិននឹងវិសាលភាពនៃការគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាពរបស់ នួន ជា ទៅលើ សោ ភឹម រស់ ញឹម និងអ្នកដទៃទៀត តាមវិធីផ្សេងក៏ដោយ ក៏គេត្រូវកត់សម្គាល់ថា អាចនឹងមានលទ្ធភាពថា សាលក្រមអាចផ្តន្ទាទោសសហជនជាប់ចោទតាមវិធីផ្សេងដែរ។ ដូចបានពិភាក្សាខាងលើ សាលក្រមមានភាពច្បាស់លាស់ក្នុងការផ្តន្ទាទោសចំពោះសហឧក្រិដ្ឋកម្មរួម ដោយផ្អែកលើទម្រង់មួយនៃការទទួលខុសត្រូវ មិនមែនផ្អែកលើការទទួលខុសត្រូវរបស់ថ្នាក់លើទេ។

28. សហមេធាវីនាំមុខទទួលស្គាល់ថា មេធាវីការពារក្តី នួន ជា មានសេរីភាពក្នុងការជ្រើសរើសសេចក្តីសន្និដ្ឋានលើអង្គហេតុ និងអង្គច្បាប់ទាំងឡាយណា ដែលពួកគេជំទាស់លើបណ្តឹងសាទុក្ខ។ ទោះជាយ៉ាងណាក្តី សារណាលើបណ្តឹងសាទុក្ខរបស់ នួន ជា មិនបានផ្តល់សំអាងហេតុ និងពីរបៀបដែលកំហុសលើអង្គហេតុ និងអង្គច្បាប់ ដែលពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់ថ្នាក់លើដែលជាស្ពានទម្ងន់ក្នុងការសម្រេចផ្តន្ទាទោស ធ្វើមោឃភាពដល់សាលក្រមផ្តន្ទាទោសដោយផ្អែកលើសហឧក្រិដ្ឋកម្មរួមនោះទេ។

## គ. ភ័ស្តុតាងបន្ថែមដែលបានស្នើសុំហួសពីវិសាលភាពពេលវេលានៃសាលក្រម

29. សហមេធាវីនាំមុខសូមលើកឡើងថា ចំនួនដ៏ច្រើននៃភ័ស្តុតាងបន្ថែមដែលសំណើបានស្នើសុំឱ្យទទួលយក និងពិចារណា ពាក់ព័ន្ធនឹងព្រឹត្តិការណ៍ និងកាលៈទេសៈនានានៅក្រោយខែ ធ្នូ ឆ្នាំ ១៩៧៧ ដែលហួសពីវិសាលភាពពេលវេលានៃសេចក្តីសន្និដ្ឋានទាក់ទិននឹងសហឧក្រិដ្ឋកម្មរួមនៅក្នុងសាលក្រមក្នុងសំណុំរឿង ០០២/០១ និងជាចុងក្រោយគឺ បណ្តឹងសាទុក្ខនេះនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល។ អ្វីដែលនៅសេសសល់នៃសហឧក្រិដ្ឋកម្មរួម និងគោលបំណងរួមនៅក្រោយខែ ធ្នូ ឆ្នាំ ១៩៧៧ និង ថាតើសហជនជាប់ចោទបានចូលរួមចំណែកនៅក្នុងគោលបំណងរួមឬយ៉ាងណា/និងរបៀបដែលគាត់បានចូលរួមចំណែកនៅក្នុងគោលបំណងរួមនោះ គឺស្ថិតនៅ

ចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២។ ហេតុនេះ សហមេធាវីនាំមុខស្នើឱ្យអង្គជំនុំជម្រះតុលាការកំពូលមេត្តាដកសេចក្តីពិចារណារបស់ខ្លួនពីភស្តុតាងដែលចុះកាលបរិច្ឆេទក្រោយខែ ធ្នូ ឆ្នាំ ១៩៧៧។

30. សហមេធាវីនាំមុខក៏សូមទាញចំណាប់អារម្មណ៍ពីអង្គជំនុំជម្រះតុលាការកំពូលផងដែរថា នាពេលបច្ចុប្បន្ន វគ្គសនាការដែលទាក់ទិននឹងការបោសសម្អាតផ្ទៃក្នុង ចរិតលក្ខណៈនៃជម្លោះប្រដាប់អាវុធ និងតួនាទីរបស់ជនជាប់ចោទទាក់ទិននឹងបទឧក្រិដ្ឋដែលបានចោទប្រកាន់នៅក្នុងវគ្គទាំងនោះ ស្ថិតនៅក្នុងកិច្ចដំណើរការនីតិវិធីសួរដេញដោលលើភស្តុតាងក្នុងសំណុំរឿង ០០២/០២[43]។ ហេតុនេះ សហមេធាវីនាំមុខស្នើសុំអង្គជំនុំជម្រះតុលាការកំពូលមេត្តាអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន ដើម្បីកុំឱ្យប៉ះពាល់ដល់កិច្ចដំណើរការនីតិវិធីលើអង្គសេចក្តីដែលកំពុងដំណើរការ និងសូមកម្រិតយុត្តាធិការលើបណ្តឹងសាទុក្ខរបស់ខ្លួនតែទៅលើកំហុសនានាដែលបានចោទប្រកាន់ ក្នុងសេចក្តីសន្និដ្ឋានលើអង្គហេតុ និងអង្គច្បាប់ ដែលសារណាលើបណ្តឹងសាទុក្ខរបស់ក្រុមមេធាវីការពារក្តីនីមួយៗបានដាក់ជូនអង្គជំនុំជម្រះពិនិត្យ។

31. សហមេធាវីនាំមុខសូមគូសបញ្ជាក់ថា ជារឿយៗសំណើសុំដាក់ជំនួសទឡ្ហីករណ៍នានាដែលមាននៅក្នុងសារណាលើបណ្តឹងសាទុក្ខរបស់ នួន ជា[44] និង ក្នុងពេលផ្សេងទៀត នាពេលសវនាការអះអាងសាជាថ្មីនូវទឡ្ហីករណ៍នានាដែលបានលើកឡើងរួចមកហើយនៅក្នុងសារណាលើបណ្តឹងសាទុក្ខរបស់ នួន ជា[45]។ សហមេធាវីនាំមុខសូមលើកឡើងថា ពុំមានកិច្ចណាមួយក្នុងចំណោមកិច្ចទាំងនេះសក្តិសមនឹងស្ថិតនៅក្នុងបរិបទនៃញត្តិស្នើសុំ និងដាក់បង្ហាញភស្តុតាងបន្ថែមលើបណ្តឹងសាទុក្ខទេ។

32. ជាគោលការណ៍ សហមេធាវីនាំមុខពុំបានជំទាស់ទៅនឹងការទទួលយក និងការពិចារណាទៅលើភស្តុតាងបន្ថែមលើបណ្តឹងសាទុក្ខដែលអាចជួយស្វែងរកការពិតបន្ថែមនោះទេ។ ទោះជាយ៉ាងណាក្តី សហមេធាវីនាំមុខសូមយោងទឡ្ហីករណ៍របស់ខ្លួនដែលពាក់ព័ន្ធនឹងតុល្យភាពរបស់ភាគី ដែលបានពន្យល់លម្អិតនៅក្នុងចម្លើយតបរបស់ខ្លួន ទៅលើសំណើសុំបំពេញកិច្ចស៊ើបសួរទាក់ទិននឹងសាក្សី

[43] សេចក្តីសម្រេចអំពីលំដាប់លំដោយនៃអង្គហេតុដែលត្រូវជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០២ ឯកសារ **E315** ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៤ ទំព័រ ៨-៩។

[44] *សូមមើល* សំណើ កថាខណ្ឌ ២៣-៦៩។

[45] សំណើ កថាខណ្ឌ ៨។

សំ សិទ្ធី[46]។ សហមេធាវីនាំមុខសូមលើកឡើងសាជាថ្មីនូវការព្រួយបារម្ភរបស់ខ្លួនអំពីភាពចាំបាច់ឲ្យមានសំណើសុំភ័ស្តុតាងបន្ថែម ដើម្បីរក្សានូវតុល្យភាពនូវសិទ្ធិរបស់ភាគី។ សហមេធាវីនាំមុខសូមជម្រុញឲ្យអង្គជំនុំជម្រះតុលាការកំពូល មេត្តាពិចារណាទៅលើការព្រួយបារម្ភទាំងនេះ នៅពេលវិនិច្ឆ័យទៅលើអង្គសេចក្ដីនៃសំណើនេះ។

## V. សំណូមពរ

**អាស្រ័យហេតុនេះ** សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសូមស្នើដោយក្ដីគោរពដល់អង្គជំនុំជម្រះតុលាការកំពូលមេត្តា៖

(១) ពិចារណាទៅលើការព្រួយបារម្ភនានាដែលបានរៀបរាប់នៅក្នុងសារណាតបនេះ នៅពេលសម្រេចទទួលយកសំណើ។

សូមលោក លោកស្រីចៅក្រមមេត្តាទទួលយកសារណាតបនេះដោយក្ដីគោរព

| កាលបរិច្ឆេទ | នាម និងគោត្តនាម | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ | ពេជ អង្គ<br>សហមេធាវីនាំមុខ | ភ្នំពេញ | |
| | Marie GUIRAUD<br>សហមេធាវីនាំមុខអន្តរជាតិ | ភ្នំពេញ | |

[46] ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ចំពោះសំណើសុំបំពេញកិច្ចស៊ើបសួរទាក់ទង សំ សិទ្ធី ឯកសារ **F28/1** ចុះថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៥ កថាខណ្ឌ ៣៧ ដល់ ៤១។